# សេចក្តីថ្លែងការណ៍របស់ស្ថានទូតអាមេរិកនៅភ្នំពេញ
# លើការប្រកាសសាលក្រម លោក កឹម សុខា

★ ★ ★ ★

សហរដ្ឋអាមេរិកមានការរំខានចិត្តជាខ្លាំង ដោយការដាក់ទោសដោយតុលាការ ទៅលើលោក កឹម សុខា ដែលជាមេដឹកនាំនយោបាយកម្ពុជាទទួលបាននូវការគោរព។

ដំណើរការក្តីដែលមានរយៈពេលច្រើនឆ្នាំ ដើម្បីបំបិទសម្លេងលោក កឹម សុខា ដោយផ្អែកលើការឃុបឃិតបែបប្រឌិត គឺជាកំហុសនៅក្នុងប្រព័ន្ធយុត្តិធម៌។

ការមិនផ្តល់ឲ្យលោក កឹម សុខា និងឥស្សរជននយោបាយដទៃទៀត នូវសេរីភាពក្នុងការបញ្ចេញមតិ និងការចូលរួម បំផ្លាញរដ្ឋធម្មនុញ្ញ ការប្តេជ្ញាចិត្តជាអន្តរជាតិ និងដំណើរជឿនលឿនកន្លងមករបស់ប្រទេសកម្ពុជា ក្នុងការពង្រឹងសង្គមមួយដែលមានពហុបក្ស និងការចូលរួមទាំងអស់គ្នា។

យើងសូមអំពាវនាវឲ្យអាជ្ញាធរអនុញ្ញាតឲ្យប្រជាជនកម្ពុជាទាំងអស់ទទួលបាននូវសិទ្ធិមនុស្សជាសាកល ក្នុងការប្រមូលផ្តុំគ្នាដោយសន្តិភាព និងសេរីភាពនៃការបញ្ចេញមតិ ហើយអនុញ្ញាតឲ្យពួកគេចូលរួមក្នុងការកសាងប្រព័ន្ធប្រជាធិបតេយ្យពិតប្រាកដមួយ។